00224887

A190/I/7

## នៅចំពោះមុខអង្គបុរេជំនុំជម្រះ
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស-អ.ប.ជ

ឈ្មោះសំណុំរឿង: **ខៀវ សំផន**

ដាក់តម្កល់ជូន: អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទដាក់ឯកសារ: ២២ កញ្ញា ២០០៨

ភាគីអ្នកតម្កល់: ក្រុមការពារក្តី

ភាសា: ភាសាបារាំង (ដើម) និងភាសាខ្មែរ (បកប្រែក្រៅផ្លូវការ)

ប្រភេទឯកសារ: សាធារណៈ

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 22 / 09 / 2008
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

---

# សារណាឆ្លើយតបរបស់ក្រុមមេធាវីការពារក្តី ស្តីពីភាពចាំបាច់ឲ្យមានសវនាការជាសាធារណៈ

---

<u>បញ្ជូនដោយ:</u>

**មេធាវីរបស់លោក ខៀវ សំផន**

មេធាវី ស សូវាន

មេធាវី Jacques VERGÈS

**ជំនួយការ៖**

អ្នកស្រី សេង សុជាតា

កញ្ញា MOREAU Charlotte

<u>បញ្ជូនទៅ:</u>

**អង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារដើមត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 09 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

# ជូនចំពោះអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម

1. ដោយបដិសេធមិនបង្គាប់ឲ្យមានការបកប្រែឯកសារសំណុំរឿងរបស់លោក ខៀវ សំផន ជាភាសាបារាំង[1] - ជាភាសាតែមួយគត់ដែលយល់បានដោយសហមេធាវីអន្តរជាតិរបស់គាត់ គឺលោក Jacques VERGÈS និងជាភាសាផ្លូវការមួយរបស់អ.វ.ត.ក - សហចៅក្រមស៊ើបអង្កេត (ស.ច.ស) បានបង្ខំលោក ខៀវ សំផន ឲ្យនៅស្ងៀមស្ងាត់ ហើយធ្វើឲ្យការការពារខ្លួនរបស់គាត់គ្មានអានុភាព។

2. សេចក្តីសម្រេចនេះបង្កឲ្យមានបញ្ហាដ៏សំខាន់ទាក់ទងនឹងសមធម៌៖ តើអ្វីទៅជាអំណាចរបស់សហ-ចៅក្រមស៊ើបអង្កេតក្នុងការដឹកនាំការស៊ើបអង្កេត? តើអ្វីទៅជាសិទ្ធិរបស់ក្រុមការពារក្តី? តើអ្វីទៅជាតួនាទីរបស់មេធាវី? តើនរណាជាអ្នកធានាការពាររងចំពោះសិទ្ធិទាំងនេះ? ហើយច្បាស់លាស់ជាងនេះ តើសិទ្ធិរបស់លោក ខៀវ សំផន ត្រូវបានគេរំលោភបំពានបែបណា? តើលោក ខៀវ សំផន ត្រូវតែដោះលែងឲ្យមានសេរីភាពវិញដែរឬទេ?

3. ទាក់ទងនឹងសំណួរទាំងនេះ អំណះអំណាងរបស់ក្រុមការពារក្តីនិងអំណះអំណាងរបស់សហព្រះរាជអាជ្ញា (ស.ព)មានភាពផ្ទុយគ្នា។ នៅពេលនេះ អង្គបុរេជំនុំជម្រះត្រូវដោះស្រាយវិវាទដ៏ស្មុគស្មាញនេះ។ អង្គបុរេជំនុំជម្រះគឺជាផ្នែកដ៏សំខាន់នៃការជជែកពិភាក្សាគ្នា ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ គឺជាការជជែកពិភាក្សាគ្នាដ៏មានសារៈសំខាន់បំផុត ទាក់ទងនឹងនីត្យានុកូលភាពនិងភាពគួរជាទីទុកចិត្តរបស់ អ.វ.ត.ក។ គឺដោយសារហេតុផលនេះហើយដែលក្រុមការពារក្តីបានស្នើឲ្យការជជែកពិភាក្សានេះប្រព្រឹត្តទៅនៅក្នុងសវនាការជាសាធារណៈ[2]។

---

[1] ដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ (តទៅនេះហៅថា "ដីកា") ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៨ *ឯកសារតុលាការ A190*

[2] ពាក្យសុំឲ្យមានសវនាការជាសាធារណៈស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធការបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន *ឯកសារតុលាការ A190/I/2*

4. សហព្រះរាជអាជ្ញា(ស.ព)ប្រឆាំងនឹងសំណើខាងលើ និងស្នើដល់អង្គបុរេជំនុំជម្រះកុំឲ្យបើកសវនាការ[3] ហើយដោយហេតុដូច្នេះ សហព្រះរាជអាជ្ញាក៏ស្ថិតនៅក្នុងភាពមិនច្បាស់លាស់រវាងសិទ្ធិ និងការបកស្រាយបំភ្លឺជាអត្ថនោម័តស្តីពីសិទ្ធិនេះ។

5. ជាការពិតណាស់ វាមិនមានហេតុផលគួរជាទីពេញចិត្តណាមួយដែលអាចបញ្ជាក់ថា ត្រូវតែដោះស្រាយវិវាទនេះដោយការពិភាក្សាដេញដោលផ្ទាល់មាត់។ អត្ថបទច្បាប់និងការអនុវត្តរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងបញ្ហានេះ បង្ហាញពីភាពផ្ទុយមួយទៅវិញ។ ម្យ៉ាងទៀត ស្ថានភាពរបស់លោក ខៀវ សំផន មានលក្ខណៈខុសប្លែកពីគេ ហើយបណ្តឹងឧទ្ធរណ៍របស់គាត់អាចបញ្ចប់ការចោទប្រកាន់។ ដោយហេតុតែពាក្យបណ្តឹងនេះចោទសួរអំពីនីត្យានុកូលភាពរបស់អ.វ.ត.ក ជាជាងអ្វីៗផ្សេងទៀតនោះ បណ្តឹងឧទ្ធរណ៍នេះទាមទារឲ្យមានជាចាំបាច់នូវការបើកសវនាការជាសាធារណៈមួយ។

6. គឺដោយហេតុដូច្នេះហើយបានជាក្រុមការពារក្តីសូមស្នើជាឱឡារិកដល់ចៅក្រមនៃអង្គបុរេជំនុំជម្រះ ឲ្យរៀបចំកិច្ចដដែកពិភាក្សាជាសាធារណៈមួយ។

## II. អង្គហេតុ និង នីតិវិធី

7. តាមរយៈដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ លោក ខៀវ សំផន ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន[4]។

8. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ សហមេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានោះ[5]។

9. សវនាការស្តីពីបណ្តឹងឧទ្ធរណ៍បានប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨។ ដោយហេតុតែអវត្តមាននៃការបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន លោក Jacques VERGÈS មិនអាចចូលរួមនៅក្នុងសវនាការនោះបាន ហើយសវនាការនោះក៏ត្រូវបានពន្យារពេល "

[3] ចម្លើយរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ (តទៅនេះហៅថា "ចម្លើយ") ថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៨ ដែលបានជូនដំណឹងជាភាសាបារាំងទៅភាគីនានា នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ កថាខ័ណ្ឌទី ៤ និង ទី៥ *ឯកសារតុលាការ A190/I/4*

[4] "ដីកាឃុំខ្លួនបណ្តោះអាសន្ន" ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ *ឯកសារតុលាការ C26*

[5] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ *ឯកសារតុលាការ C26/I/3*

ទៅកាលបរិច្ឆេទមួយដែលមិនទាន់កំណត់នៅឡើយ”។ ហើយចាប់ពីពេលនោះមក ពុំមានសវនាការណាមួយត្រូវបានគ្រោងធ្វើឡើយ។[6]

10. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានបង្គាប់បញ្ជាមកក្រុមការពារក្តី ឲ្យធ្វើសេចក្តីកត់សម្គាល់របស់ខ្លួនទាក់ទងនឹងសភាពនៃអង្គហេតុនេះ[7]។ នៅថ្ងៃទី២១ ខែសីហា ក្រុមការពារក្តីបានបញ្ជាក់នូវគោលជំហររបស់ខ្លួនឡើងវិញ ស្តីពីភាពចាំបាច់ក្នុងការទទួលបានការបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន[8]។

11. ហើយទន្ទឹមគ្នានោះ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីនីមួយៗទាក់ទងនឹងការបកប្រែ[9]។ តាមការពិត ដីកាសម្រេចនោះបានបដិសេធសំណើសុំបកប្រែរបស់លោក ខៀវ សំផន។

12. ភ្លាមៗនោះ សហមេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាខាងលើនេះ ដោយស្នើដល់អង្គបុរេជំនុំជម្រះឲ្យទុកជាមោឃៈនូវដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដោយសារកង្វះមូលដ្ឋានច្បាប់ និងឲ្យកត់សម្គាល់អំពីការរំលោភដ៏ធ្ងន់ធ្ងរទៅលើសិទ្ធិរបស់លោក ខៀវ សំផន ព្រមទាំងបង្គាប់ឲ្យមានការដោះលែងគាត់ឲ្យមានសេរីភាពដោយគ្មានលក្ខខណ្ឌ ដោយសារតែកំហុសនីតិវិធីដ៏ធ្ងន់ធ្ងរ[10]។

13. នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានដាក់សំណើមួយ ដើម្បីឲ្យបណ្តឹងឧទ្ធរណ៍ខាងលើនេះប្រព្រឹត្តទៅជាសាធារណៈ ព្រោះថាការជាប់ពាក់ព័ន្ធរបស់ខ្លួនអាចមានសារៈសំខាន់ជាចំបងសម្រាប់នីតិវិធីទាំងមូល[11]។

---

[6] សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលសវនាការ ទាក់ទងនឹងការពិនិត្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/25*

[7] “សេចក្តីជូនដំណឹងទៅក្រុមការពារក្តី ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួនបណ្តោះអាសន្ន” - *ឯកសារតុលាការ C26/I/27*

[8] សេចក្តីជូនដំណឹងស្តីពីគោលជំហររបស់ក្រុមការពារក្តី ទៅអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន *ឯកសារតុលាការ C26/I/28*

[9] ដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ *ឯកសារតុលាការ A190*

[10] សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តីប្រឆាំងនឹងការបដិសេធការបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ *ឯកសារតុលាការ A190/I/1*

[11] ពាក្យសុំឲ្យមានសវនាការជាសាធារណៈស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធការបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ *ឯកសារតុលាការ A190/I/2*

14. នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់ចម្លើយរបស់ខ្លួន ឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ដោយស្នើទៅអង្គបុរេជំនុំជម្រះឲ្យ "បដិសេធបណ្តឹងឧទ្ធរណ៍ [របស់ក្រុមការពារក្តី] ដោយសម្អាងហេតុផលថាបណ្តឹងឧទ្ធរណ៍នេះ គឺមិនអាចទទួលយកបាន ផ្នែកនីតិវិធី និងគ្មានមូលហេតុច្បាស់លាស់។"[12]

15. ជាបឋម ការិយាល័យសហព្រះរាជអាជ្ញាក៏ប្រឆាំងផងដែរ ចំពោះការប្រព្រឹត្តិទៅនូវសវនាការមួយសម្រាប់បណ្តឹងឧទ្ធរណ៍នេះ។ ការិយាល័យសហព្រះរាជអាជ្ញាបានស្នើទៅអង្គបុរេជំនុំជម្រះ ឲ្យធ្វើការដោះស្រាយលើវិវាទនេះ ត្រឹមតែដោយសម្អាងទៅលើសារណាជាលាយលក្ខណ៍អក្សរប៉ុណ្ណោះបានហើយ ដោយធ្វើរួមគ្នាជាមួយនឹងបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី [13]។

16. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានបង្គាប់ "ទៅសហមេធាវីរបស់ជនត្រូវចោទឲ្យដាក់ ប្រសិនបើមាន នូវចម្លើយតបទៅនឹងកថាខ័ណ្ឌ ៤ និង ៥ នៃចម្លើយរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងនេះ។"

17. កថាខ័ណ្ឌទាំងនោះមានដូចតទៅនេះ៖

*មិនតម្រូវឲ្យមានសវនាការផ្ទាល់មាត់ទេ*

៤. សហព្រះរាជអាជ្ញា ស្នើថា ពុំចាំបាច់មានសវនាការផ្ទាល់មាត់ទេ ព្រោះថា ភាគីនានាធ្លាប់បានដាក់សារណាស្តីពីអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍នេះយ៉ាងគ្រប់គ្រាន់ជូនទៅអង្គបុរេជំនុំជម្រះរួចហើយ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ សម្រេចកំណត់បណ្តឹងឧទ្ធរណ៍នេះ ត្រឹមតែជាសេចក្តីសំអាងជាលាយលក្ខអក្សរប៉ុណ្ណោះបានហើយ។ សេចក្តីណែនាំអនុវត្តសម្រាប់ការដាក់ឯកសារ ("សេចក្តីណែនាំអនុវត្ត") និងការអនុវត្តន៍របស់អង្គបុរេជំនុំជម្រះលើករណីស្រដៀងគ្នានេះបានអនុញ្ញាតឲ្យប្រើអំណាចបែបនេះ។

៥. ដើម្បីជាប្រយោជន៍សេដ្ឋកិច្ចរបស់អង្គជំនុំជម្រះនេះ សហព្រះរាជអាជ្ញា ស្នើឲ្យធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ រួមគ្នាជាមួយនឹងបណ្តឹងឧទ្ធរណ៍ដែល អៀង សារី បានដាក់ជូនស្តីពីសេចក្តីសម្រេចទាក់ទងនឹងការបកប្រែនេះដែរ។ បណ្តឹងឧទ្ធរណ៍ទាំងពីរនេះ បានលើកឡើងអំពីបញ្ហាអង្គច្បាប់ និងអង្គហេតុស្រដៀងគ្នា។

18. នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ ក្រុមការពារក្តីបានដាក់ចម្លើយតបនេះ។

---

[12] ចម្លើយរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ (តទៅនេះហៅថា "ចម្លើយរបស់ ស.ព") ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៨ ដែលបានជូនដំណឹងជាភាសាបារាំងទៅភាគីនានា នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ *ឯកសារតុលាការ A190/I/4*

[13] ចម្លើយរបស់សហព្រះរាជអាជ្ញា កថាខ័ណ្ឌ ៤ និង ៥

## III. ច្បាប់អនុវត្តន៍

19. វិធាន ៧៧.៣ នៃវិធានផ្ទៃក្នុង ចែងថា "ប្រធានអង្គបុរេជំនុំជម្រះ (...) កំណត់កាលបរិច្ឆេទសវនាការ ហើយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ ត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ភាគី និង មេធាវីរបស់ភាគីទាំងនោះ"[14]។

20. ដោយឡែក វិធាន ៧៧(៦) នៃវិធានផ្ទៃក្នុង ចែងថា "តាមសំណើរបស់ចៅក្រមណាម្នាក់ ឬរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចថា នីតិវិធីទាំងស្រុង ឬ មួយផ្នែកនៃសវនាការត្រូវធ្វើឡើងជាសាធារណៈ ជាពិសេសនៅពេលដែលសំណុំរឿងនោះអាចត្រូវបានបញ្ចប់ ដោយសេចក្ដីសម្រេចរបស់ខ្លួន ដូចជា ពាក្យបណ្ដឹងឧទ្ធរណ៍ ឬ ពាក្យសុំពាក់ព័ន្ធទៅនឹងបញ្ញាយុត្តាធិការ ឬ មូលហេតុ ដែលនាំឲ្យរលត់បណ្ដឹងអាជ្ញា បើអង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬ វិធានការការពាររបស់តុលាការ។"

21. ទន្ទឹមគ្នានេះ វិធាន ៨.៤ នៃសេចក្ដីណែនាំអនុវត្តន៍ ០១/២០០៧ វិសោធនកម្មលើកទី២ ចុះថ្ងៃទី៥ ខែ តុលា ឆ្នាំ២០០៧ (តទៅនេះហៅថា សេចក្ដីណែនាំអនុវត្តន៍) ចែងថា "សំណើឆ្លើយតបចំពោះសារណាតបនឹងត្រូវអនុញ្ញាត នៅក្នុងករណីតែមិនមានការស្នើសុំអោយមានការដេញដោលដោយផ្ទាល់មាត់។"

22. នៅទីបញ្ចប់ មាត្រា ១៤.១ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (PIDCP) ដែលអាចអនុវត្តន៍បានដោយផ្ទាល់នៅក្នុងច្បាប់ក្នុងប្រទេស ចែងថា "ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្ដីមានសមត្ថកិច្ច ជំនុះជំរះរឿងក្ដីរបស់ខ្លួន ដោយសមធម៌និងជាសាធារណៈ។"[15]

## IV. អំណះអំណាងសម្រាប់ចម្លើយតប

23. នៅក្នុងចម្លើយរបស់ខ្លួន សហព្រះរាជអាជ្ញាយល់ឃើញថា វិវាទគួរត្រូវដោះស្រាយជាលាយលក្ខណ៍អក្សរ ហើយធ្វើឡើងនៅក្នុងពេលជាមួយគ្នានឹងបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី។ បើតាមក្រុម

---

[14] សូមអាន មាត្រា ២៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដូចដែលត្រូវបានកែប្រែនៅពេលថ្មីៗនេះ

[15] សូមអានផងដែរ មាត្រា ៦.១ នៃអនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (CEDH) ដែលចែងថា "ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្ដីឯករាជ្យនិងមិនលម្អៀង ជំនុំជម្រះរឿងក្ដីរបស់ខ្លួន ដោយសមធម៌ ជាសាធារណៈ និងនៅក្នុងរយៈពេលមួយសមស្រប"

ការពារក្តី នេះគឺជាសំណើមួយដែលមានភាពងាយស្រួលហួសហេតុ ហើយមិនមានអ្វីមួយដែលបញ្ជាក់ថាសំណើនេះត្រឹមត្រូវឡើយ។

24. ជាបឋម សហព្រះរាជអាជ្ញាយល់ឃើញថា "សេចក្តីណែនាំអនុវត្តន៍ (...) និងការអនុវត្តរបស់អង្គបុរេជំនុំជម្រះលើករណីស្រដៀងគ្នានេះបានអនុញ្ញាតឲ្យប្រើអំណាចបែបនេះ"។ បើតាមយោបល់របស់សហព្រះរាជអាជ្ញា "ពុំចាំបាច់មានសវនាការផ្ទាល់មាត់ទេ ព្រោះថា ភាគីនានាធ្លាប់បានដាក់សារណាស្តីពីអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍នេះយ៉ាងគ្រប់គ្រាន់ជូនទៅអង្គបុរេជំនុំជម្រះរួចហើយ"។[16]

25. ទាំងអត្ថបទច្បាប់ដែលអាចអនុវត្តន៍បាននៅចំពោះមុខ អ.វ.ត.ក ទាំងការអនុវត្តរបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបញ្ហានេះ ហាក់ដូចជាមិនអាចបញ្ជាក់ថា សេចក្តីសន្និដ្ឋានមួយបែបនេះត្រឹមត្រូវឡើយ។

## ១- អត្ថបទច្បាប់គ្រោងឲ្យមានការប្រព្រឹត្តិទៅនៃសវនាការ

26. ទាក់ទងនឹងកាលបរិច្ឆេទនៃការដាក់ពាក្យសុំរបស់ក្រុមការពារក្តី និងនៃចម្លើយរបស់សហព្រះរាជអាជ្ញា វិធាន ៧៧ (៣) នៃវិធានផ្ទៃក្នុង ក៏ដូចជាមាត្រា ២៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងយ៉ាងច្បាស់អំពីការប្រព្រឹត្តិទៅនៃសវនាការ នៅក្នុងករណីមានបណ្តឹងឧទ្ធរណ៍[17]។ ដោយអនុលោមតាមអត្ថបទច្បាប់ទាំងនេះ នៅពេលណាដែលបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ ជាគោលការណ៍ អង្គបុរេជំនុំជម្រះត្រូវរៀបចំការជជែកពិភាក្សា។

27. ប៉ុន្តែ នៅក្នុងការអនុវត្ត នៅក្នុងករណីដែលខ្លួនយល់ថាសមស្រប អង្គបុរេជំនុំជម្រះបានសម្រេចដោះស្រាយត្រឹមតែជាសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។ ម្យ៉ាងទៀត អត្ថបទថ្មីនៃវិធាន ៧៧.៣ នៃវិធានផ្ទៃក្នុង ដែលបានចូលជាធរមាននៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ បង្ហាញឲ្យឃើញនូវការអនុវត្តនេះ ដោយហេតុថាអង្គបុរេជំនុំជម្រះ "បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភាគីនានា អាច

---

[16] កថាខ័ណ្ឌ ៤ និង ៥ នៃចម្លើយរបស់សហព្រះរាជអាជ្ញា

[17] មាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តន៍ដែលលើកឡើងដោយសហព្រះរាជអាជ្ញា ចែងដោយពិតប្រាកដថា "សំណើឆ្លើយតបចំពោះសារណាតបនឹងត្រូវអនុញ្ញាត នៅក្នុងករណីតែមិនមានការស្នើសុំអោយមានការដេញដោលដោយផ្ទាល់មាត់"។ ប៉ុន្តែ ពុំមានអ្វីមួយចែងថា តើនៅក្នុងវិធានការបែបណាដែលមាត្រានេះអាចអនុវត្តន៍បាននៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយថាតើនៅក្នុងករណីណាខ្លះដែលការដេញដោលដោយផ្ទាល់មាត់ មានភាពចាំបាច់។

[ចាប់ពីពេលនេះទៅ] សម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំ ដោយសម្អាងលើសេចក្តីកត់សម្គាល់ជាលាយលក្ខណ៍អក្សររបស់ភាគីនានាតែប៉ុណ្ណោះ"។

28. ប៉ុន្តែ និងដូចដែលអង្គបុរេជំនុំជម្រះនឹងយល់ស្រប សេចក្តីសម្រេចទាំងនេះតែងតែកើតមានឡើង នៅក្នុងក្របខណ្ឌដ៏ច្បាស់លាស់មួយដែលតាមពិតទៅ បញ្ជាក់អំពីសារៈសំខាន់នៃការជជែកពិភាក្សានៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។

## ២- ការអនុវត្តបង្ហាញពីការរៀបចំសវនាការមួយ

29. ដើម្បីប្រឆាំងនឹងការរៀបចំសវនាការផ្ទាល់មាត់មួយ សហព្រះរាជអាជ្ញាលើកឡើងអំពីការអនុវត្តរបស់អង្គជំនុំជម្រះ។ បើយោងតាមសហព្រះរាជអាជ្ញា "ពុំចាំបាច់ឱ្យមានសវនាការផ្ទាល់មាត់ទេ" នៅពេលដែល "ភាគីនានាធ្លាប់បានដាក់សារណាស្តីពីអង្គហេតុ និងអង្គច្បាប់ ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍នេះយ៉ាងគ្រប់គ្រាន់ជូនទៅអង្គបុរេជំនុំជម្រះរួចហើយ"។

30. នេះហាក់ដូចជាអំណះអំណាងតែមួយគត់ដែលសហព្រះរាជអាជ្ញាលើកឡើង ដោយហេតុថាខ្លួនមិនបានពន្យល់អំពីអ្វីដែលអង្គបុរេជំនុំជម្រះអាចចាត់ទុកថាមានព័ត៌មានគ្រប់គ្រាន់ ហើយក៏មិនបានពន្យល់ថាហេតុអ្វីការគិតដូច្នេះអាចនាំឱ្យមិនចាំបាច់មានសវនាការផ្ទាល់មាត់នោះ។

31. បើតាមសហព្រះរាជអាជ្ញាវិញ គឺជាការគ្រប់គ្រាន់ដែលភាគីនានាបានដាក់សារណារបស់ខ្លួនជាលាយលក្ខណ៍អក្សរ (ដូចដែលភាគីនានាធ្លាប់ធ្វើរាល់ដងនោះ) ដើម្បីឱ្យអង្គបុរេជំនុំជម្រះយល់ឃើញថាបានព័ត៌មានគ្រប់គ្រាន់ ហើយមិនចាំបាច់សាកសួរភាគីនានាទៀតទេ។ ការវិភាគយ៉ាងដូច្នេះ នាំឱ្យមានទស្សនៈមួយដ៏ចង្អៀតចង្អល់ស្តីពីតួនាទីនៃការពិភាក្សាតទល់គ្នានៅពេលសវនាការផ្ទាល់មាត់ ហើយម្យ៉ាងទៀត ការវិភាគយ៉ាងដូច្នេះមិនសមស្របតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងបញ្ហានេះទេ។

32. ជាការពិតណាស់ ដើម្បីសម្រេចដោះស្រាយដោយគ្មានការពិភាក្សាដេញដោល អង្គបុរេជំនុំជម្រះត្រូវតែចាត់ទុកថា ខ្លួនមានព័ត៌មានយ៉ាងគ្រប់គ្រាន់ស្តីពីអង្គហេតុនិងអង្គច្បាប់។ បើមិនដូច្នេះទេ តើអង្គបុរេជំនុំជម្រះអាចធ្វើការសម្រេចយ៉ាងដូចម្តេចបាន? ប៉ុន្តែ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះគោរពសិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវទទួលបានការជំនុំជម្រះក្តីជាសាធារណៈ និងដោយសមធម៌។ បើតាមអ្វីដែលក្រុមមេធាវីការពារក្តីបានដឹង អង្គបុរេជំនុំជម្រះតែងតែបានធ្វើការសម្រេចទៅលើបណ្តឹងឧទ្ធរណ៍

ណាមួយ ដោយសំអាងតែទៅលើសារណាជាលាយលក្ខអក្សរប៉ុណ្ណោះ នៅពេលដែលមានការស្នើសុំដោយជាក់លាក់ពីជនត្រូវចោទ[18] ហើយដោយមានយ៉ាងហោចណាស់ការយល់ស្របរបស់ភាគីទាំងពីរ។[19]

33. នៅក្នុងករណីដែលសហព្រះរាជអាជ្ញាបានស្នើសុំដូច្នេះ អង្គបុរេជំនុំជម្រះតែងតែបានពិនិត្យយ៉ាងត្រឹមត្រូវថាជនត្រូវចោទមិនប្រឆាំងទេ។[20] ម្យ៉ាងទៀត អ្វីដែលត្រូវដោះស្រាយនៅក្នុងករណីទាំងនោះគឺមានកំណត់។ ជាឧទាហរណ៍ នៅក្នុងសេចក្តីសម្រេចដែលសហព្រះរាជអាជ្ញាលើកឡើងនោះ អង្គបុរេជំនុំជម្រះបានរំលឹកយ៉ាងត្រឹមត្រូវថាៈ "ទោះបីជា [សហព្រះរាជអាជ្ញា]មិនយល់ស្របនឹងអំណះអំណាងស្តីពីអង្គច្បាប់ និងអង្គហេតុដែលមេធាវីលើកឡើង" ប៉ុន្តែបើនិយាយពីគោលការណ៍ សហព្រះរាជអាជ្ញា "មិនបានប្រឆាំងនឹងបណ្តឹងឧទ្ធរណ៍" របស់ក្រុមមេធាវីការពារក្តីទេ។ អង្គបុរេជំនុំជម្រះក៏បានលើកឡើងផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់ចម្លើយណាមួយទេ។[21]

34. ការអនុវត្តបង្ហាញថា អង្គបុរេជំនុំជម្រះមិនដែលបានបដិសេធមិនឲ្យមានសវនាការ ចំពោះភាគីណាមួយទេ ជាពិសេសចំពោះជនត្រូវចោទ។ អង្គបុរេជំនុំជម្រះស្ថិតនៅក្នុងស្ថានភាពថ្មីមួយ ខុសប្លែកពីស្ថានភាពដែលបានលើកឡើងខាងលើនេះ។

---

[18] សូមអានជាអាទិ៍ (ការបកប្រែក្រៅផ្លូវការ) សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី២ប ខែកញ្ញា ឆ្នាំ២០០៨ *ឯកសារតុលាការ A190/II/7*។ សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ស្តីពីលក្ខខណ្ឌនៃការឃុំខ្លួន ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨ *ឯកសារតុលាការ C33/I/15*។ សេចក្តីសម្រេចស្តីពីកាលបរិច្ឆេទថ្មីនៃសវនាការ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ (ការបកប្រែក្រៅផ្លូវការ) *ឯកសារតុលាការ D55/I/6* ។

[19] សូមអានជាអាទិ៍ សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ស្តីពីការតែងតាំងអ្នកអ្នកជំនាញ ដោយផ្អែកលើលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨ *ឯកសារតុលាការ D54/V/4* ។

[20] ស្ថានភាពនេះបានកើតឡើងនៅក្នុងករណីដែលសហព្រះរាជអាជ្ញាបានលើកឡើង សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងទំនាក់ទំនងរវាងជនត្រូវចោទនិងប្រពន្ធរបស់គាត់ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ *ឯកសារតុលាការ A104/II/7* ហើយក៏បានកើតឡើងនៅក្នុងករណីផ្សេងទៀតដែរ។ សូមអានជាអាទិ៍ សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៨ *ឯកសារតុលាការ A162/III/5*។

[21] សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងទំនាក់ទំនងរវាងជនត្រូវចោទនិងប្រពន្ធរបស់គាត់ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ *ឯកសារតុលាការ A104/II/7* កថាខ័ណ្ឌទី៦ និង៧។

35. ស្ថានភាពនៃបណ្តឹងឧទ្ធរណ៍នេះ ខុសពីស្ថានភាពមុនៗ ហើយអ្វីដែលត្រូវដោះស្រាយនៅក្នុងការពិភាក្សាតទល់គ្នានេះក៏មានសារៈសំខាន់ខ្លាំងដែរ។ លោក ខៀវ សំផន បានស្នើសុំយ៉ាងជាក់លាក់ទៅអង្គបុរេជំនុំជម្រះ ឲ្យបើកសវនាការ។ គាត់ក៏បានស្នើទៅអង្គបុរេជំនុំជម្រះឲ្យពិនិត្យពិចារណាលើលក្ខណៈពិសេសនៃពាក្យបណ្តឹងនេះ ដើម្បីឲ្យមានសវនាការជាសាធារណៈមួយ។ ទាក់ទងនឹងអត្ថន័យវិញ វាជាការច្បាស់ណាស់ដែលភាគីនានាមិនយល់ស្របទាល់តែសោះ។

36. នៅទីបំផុត សហព្រះរាជអាជ្ញាលើកឡើងអំពីការអនុវត្តរបស់អង្គបុរេជំនុំជម្រះយ៉ាងដូច្នេះ មិនមែនដោយសារការអនុវត្តនេះមានការពាក់ព័ន្ធនឹងករណីរបស់យើងនោះទេ ប៉ុន្តែគឺដោយសារសហព្រះរាជអាជ្ញាគ្មានហេតុផលគួរយកជាការបានណាមួយ ដើម្បីសុំប្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរ។

## ៣- សំណើសុំឲ្យមានសវនាការជាសាធារណៈរបស់លោក ខៀវ សំផន ពិតជាមានមូលដ្ឋានគតិយុត្តិត្រឹមត្រូវ

37. ក៏ដូចបានបង្ហាញជូន នៅក្នុងសំណើសុំឲ្យមានសវនាការជាសាធារណៈរបស់ក្រុមមេធាវីការពារក្តីបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន នេះពិតជាបានចូលក្នុងលក្ខខណ្ឌដូចដែលបានកំណត់ក្នុងវិធាន ៧៧(៦) នៃវិធានផ្ទៃក្នុង។ សហមេធាវីការពារក្តីសូមឲ្យអង្គបុរេជំនុំជម្រះ មេត្តាពិនិត្យលើអំណះអំណាងដែលបានលើកឡើងអំពីចំណុចនេះ ក្នុងសំណើសុំរបស់ខ្លួន[22]។

38. ផ្ទុយមកវិញ សំណើសុំដែលបានលើកឡើងដោយស.ព ដែលថា "ដើម្បីជាផលប្រយោជន៍សេដ្ឋកិច្ចរបស់អង្គជំនុំជម្រះនេះ(...) សម្រេចរួមគ្នាជាមួយនឹងបណ្តឹងឧទ្ធរណ៍ដែល អៀង សារី បានដាក់ជូនស្តីពីសេចក្តីសម្រេចទាក់ទងការបកប្រែនេះដែរ[23]" ពុំមានមូលដ្ឋានច្បាប់ត្រឹមត្រូវនោះឡើយ។

39. លោក ខៀវ សំផន មានបំណងបង្ហាញខ្លួននៅមុខចៅក្រមទាំងអស់ ចំណែកលោក អៀង សារី វិញ ផ្ទុយមកវិញ គាត់បែរជាចង់ឲ្យចៅក្រមសម្រេចសេចក្តីលើអំណះអំណាងជាលាយល័ក្ខអក្សររបស់ខ្លួន

---

[22] "ពាក្យសុំឲ្យមានសវនាការជាសាធារណៈនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធបកប្រែសំណុំរឿងលោក ខៀវ សំផន" ឯកសារតុលាការ A190/I/2

[23] សំណុំរឿង អៀង សារី បណ្តឹងឧទ្ធរណ៍លោក អៀង សារីប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-កសចស(អបជ១២) ថ្ងៃទី២២ កក្កដា ២០០៨។

ទៅវិញ-ដែលជាអ្វីដែលគាត់ត្រូវបានអនុញ្ញាត[24]។ ប្រសិនបើដូចនឹងអ្វីដែលបានលើកឡើងដោយស.ព ដែលថា រឿងក្តីទាំងពីរនេះដូចគ្នាបេះបិទ តើគោលការណ៍សមធម៌មិនបានដាក់កំហិតទេថា អ្វីដែលបានអនុញ្ញាតដល់អ្នកណាម្នាក់ ត្រូវតែអនុញ្ញាតដូចគ្នាដល់អ្នកណាម្នាក់ផ្សេងទៀត? តើអ្វីដែលថា សំណើសុំរបស់លោក អៀង សារី ក្នុងការទទួលបានការកាត់ក្តីជាលាយល័ក្ខណ៍អក្សរ មានលក្ខណៈត្រឹមត្រូវស្របច្បាប់ជាង សំណើសុំរបស់លោក ខៀវ សំផន ក្នុងការទទួលបានការកាត់ក្តីជាសាធារណៈនោះ? ជាថ្មីម្តងទៀត តើយើងត្រូវទុកចោលគោលការណ៍គ្រឹះនៃនីតិវិធីតុលាការឲ្យបាត់បង់ដោយសារបញ្ហាហិរញ្ញវត្ថុឬ?

40. មេធាវីការពារមិនជឿថាដូច្នោះឡើយ។ ខ្លួនយល់ឃើញថា វាពុំពិតប្រាកដសោះដែលនិយាយថា "ជនត្រូវចោទទាំងពីរលើកឡើងនូវចំណុចអង្គហេតុ និងអង្គច្បាប់ដូចគ្នា។"

41. ប្រសិនបើរឿងក្តីទាំងពីរនេះដូចគ្នាបេះបិទតែម្តង យើងអាចចោទជាសំណួរយ៉ាងស្របច្បាប់លើការដែលការិយាល័យស.ព បានដាក់ចម្លើយតបពីរ។ ពិតប្រាកដណាស់ ជនត្រូវចោទទាំងពីរទាមទារសិទ្ធិដូចគ្នា - តើវាពុំពិតទេឬ? - ប៉ុន្តែកាលៈទេសៈរបស់ពួកគេខុសគ្នាជាខ្លាំង។

42. លោក ខៀវ សំផន បានបាត់បង់នូវលក្ខការណ៍នៃបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្នរបស់គាត់។ ដោយសារតែអវត្តមាននៃការបកប្រែសំណុំរឿង លោកមេធាវី VERGÈS ពុំអាចចូលរួមក្នុងសវនាការបណ្តឹងឧទ្ធរណ៍កាលពីថ្ងៃទី២៣ ខែមេសា ហើយគាត់នៅតែមិនអាចអានឯកសារភស្តុតាងក្នុងសំណុំរឿងស៊ើបអង្កេតបានដដែល។ ដូច្នេះ អស់រយៈពេលជិត១១ខែហើយ លោក ខៀវ សំផន ត្រូវបានឃុំខ្លួនបណ្តោះអាសន្នដោយផ្អែកលើដីកាសម្រេចមួយ ដែលនីត្យានុកូលភាពនៃដីកានោះពុំត្រូវបានយល់ស្របតាមនោះឡើយ។ នេះពុំដូចករណីលោក អៀង សារី នោះឡើយ។ លោក ខៀវ សំផន ក៏បានស្នើសុំទៅអង្គបុរេជំនុំជម្រះឲ្យដោះលែងគាត់ឲ្យមានសេរីភាពជាបន្ទាន់ ដោយមូលហេតុកំហុសនីតិវិធី។ ដោយឡែក លោក អៀង សារី ពុំបានសុំឲ្យមានវិធានការណ៍នេះឡើយ។

43. ស្ថានភាពលោក ខៀវ សំផន មានតែមួយគត់ ហើយបញ្ហាទាំងឡាយដែលចោទសួរក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់មានសារសំខាន់ណាស់។ រីឯការដែលលោក អៀង សារី ជ្រើសរើសឲ្យចៅក្រមមិនស្តាប់គាត់នោះ គឺជាសេរីភាពរបស់គាត់។ វាពុំមានយុត្តិកម្មណាមួយ ដើម្បីឲ្យជម្រើសនេះមានផលវិបាកលើរឿងក្តីលោក ខៀវ សំផន នោះឡើយ។

[24] សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍លោក អៀង សារី ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយល័ក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី១០ កញ្ញា ២០០៨ ឯកសារតុលាការលេខ A190/II /7។

## ៤- សំណើសុំឱ្យមានសវនាការជាសាធារណៈរបស់លោក ខៀវ សំផន ស្របច្បាប់

44. ផ្ទុយនឹងសហព្រះរាជអាជ្ញា សហមេធាវីការពារក្ដីយល់ស្របតាមសារសំខាន់យ៉ាងខ្លាំង ក្នុងការឱ្យមានការពិភាក្សាដេញដោលជាសាធារណៈលើបណ្ដឹងឧទ្ធរណ៍នេះ ប៉ុន្តែមានលក្ខណៈដូចគ្នា និងយ៉ាងទូលាយ នៅចំពោះមុខអ.វ.ត.ក[25]។

45. សហមេធាវីជឿថា "សិទ្ធិរបស់ជនជាប់ចោទ (បានសរសេរថាដូច្នេះ) ក្នុងការទទួលបានសវនាការជាសាធារណៈមិនគ្រាន់តែតំណាងនូវការធានា ជាជាងការដែលយើងខំប្រឹងប្រែងរកការពិតឡើយ៖ វាក៏បានរួមចំណែកផងដែរ ក្នុងការអះអាងដល់ជនជាប់ចោទថា មូលហេតុរបស់គាត់ត្រូវបានស្ដាប់ដោយតុលាការដែលប្រកបដោយឯករាជ្យភាព និងអព្យាក្រិតភាព។ ការផ្សាយជាសាធារណៈនៃនីតិវិធីអង្គតុលាការ ការពារអ្នកជាប់ពាក់ព័ន្ធនឹងតុលាការ ពីយុត្តិធម៌ជាសម្ងាត់ដែលរួចផុតពីការពិនិត្យរបស់សាធារណជន ហើយវាក៏ជាមធ្យោបាយមួយផងដែរ ដើម្បីរក្សាការពារទំនុកចិត្តនៅតុលាការថ្នាក់ក្រោម និងតុលាការថ្នាក់លើ។ តាមរយៈតម្លាភាពដែលខ្លួនផ្ដល់ឱ្យដល់ការគ្រប់គ្រងយុត្តិធម៌ ការផ្សព្វ-ផ្សាយនេះក៏ជួយសម្រេចបំណងនៃមាត្រា៦ កថាខណ្ឌ១ (អនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស)៖ការកាត់ក្ដីប្រកបដោយយុត្តិធម៌ ដែលធានាដោយគោលការណ៍ទាំងឡាយនៃសង្គមប្រជាធិបតេយ្យទាំងមូលតាមន័យនៃអនុសញ្ញា (...)[26]"

46. ដូចបានរំលឹកឡើងក្នុងផ្ដើមសេចក្ដី បណ្ដឹងឧទ្ធរណ៍លោក ខៀវ សំផន គឺជាបញ្ហាស្នូលនៃការកាត់ក្ដីប្រកបដោយយុត្តិធម៌។ តាមយោបល់នៃអ្នកជំនាញ "ការកាត់ក្ដីលើមេដឹកនាំខ្មែរក្រហមត្រូវស្របតាមពាក្យស្លោកដែលថា ការប្រព្រឹត្តទៅនៃយុត្តិធម៌ពុំគ្រប់គ្រាន់ឡើយ តែការអនុវត្តនៃយុត្តិធម៌នោះត្រូវតែបង្ហាញឱ្យឃើញជាសាធារណៈ។ ដើម្បីឱ្យយុត្តិធម៌ព្រហ្មទណ្ឌដើរតួដូចអ្វីដែលបានបរិយាយក្នុងសេចក្ដីផ្ដើមនៃរបាយការណ៍របស់យើងនេះ ប្រជាជនកម្ពុជាត្រូវមានទំនុកចិត្តលើសមធម៌នៃនីតិវិធី។ បើមិនដូច្នោះទេ វានឹងត្រូវបានចាត់ទុកថា គ្រាន់តែជាកិច្ចការនយោបាយមួយតែប៉ុណ្ណោះ។ ដោយឡែក ឱកាស

---

[25] សំណូមពររបស់ស.ពក្នុងការផ្សាយ " (សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ)ក្នុងគេហទំព័ររបស់អ.វ.ត.ក ក្នុងពេលជាមួយគ្នានឹងឯកសារដ៏ទៃទៀតក្នុងក្របខណ្ឌនៃបណ្ដឹងឧទ្ធរណ៍នេះ" គឺពុំគ្រប់គ្រាន់ឡើយ (កថាខណ្ឌ ៦)។

[26] គណៈកម្មធិការសិទ្ធិមនុស្សអឺរ៉ុប ករណី Roberto Marra និងPaola Gabrielli តទល់នឹង Saint-Marin របាយការណ៍របស់គណៈកម្មាធិការអនុម័តនៅថ្ងៃទី៣០ វិច្ឆិកា ១៩៩៨ កថាខណ្ឌ៤៩ និង៥០

នៃចំណេះដឹងដែលទាញចេញពីសាលក្រមប្រកបដោយយុត្តិធម៌ និងអញ្ញាក្រិត ដែលប្រជាជនកម្ពុជាអាចទទួលយកបាន នឹងត្រូវកាត់បន្ថយប្រសិនបើពួកគេពុំមានទំនុកចិត្តលើនីតិវិធី"។[27]

47. នៅពេលដែលប្រជាជនកម្ពុជាចោទសួរទៅខ្លួនឯងជាលម្អិត លើភាពដែលអាចគួរឱ្យទុកចិត្តបាន និងភាពស្របច្បាប់របស់អ.វ.ត.ក ការចាំបាច់នៃការពិភាក្សាដេញដោលជាសាធារណៈរឹតតែកើនឡើងថែមទៀត។ សហមេធាវីការពារក្តីជឿថា អង្គបុរេជំនុំជម្រះដឹងពីកម្រិតនៃសារសំខាន់នៃសេចក្តីសម្រេចរបស់ខ្លួនលើបញ្ហានេះ។

## IV. សេចក្តីសន្និដ្ឋាន

48. ដោយហេតុដូច្នេះ សហមេធាវីការពារក្តីសូមស្នើជាឱឡារិកទៅចៅក្រមអង្គបុរេជំនុំជម្រះមេត្តា៖

- ពិនិត្យលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក ខៀវ សំផន ដោយឡែកពីគ្នា
- ពិចារណាជាមួយក្រុមការពារក្តីថា បណ្តឹងឧទ្ធរណ៍លោក ខៀវ សំផន តម្រូវឱ្យមានសវនាការជាសាធារណៈ
- កំណត់កាលបរិច្ឆេទសវនាការដែលធានាឱ្យមានការចូលរួមទាំងស្រុង និងពេញទំហឹងពីសំណាក់ក្រុមការពារក្តី។

សម្រាប់សហមេធាវីការពារក្តីឱ្យលោក ខៀវ សំផន

មេធាវី ស សូវាន

---

[27] របាយការណ៍របស់ក្រុមជំនាញការសម្រាប់ប្រទេសកម្ពុជា ដោយសេចក្តីសម្រេច ៥២/១៣៥ របស់សន្និបាតអង្គការសហប្រជាជាតិ ភ្ជាប់ជាឧបសម្ព័ន្ធទៅឯកសារលេខ A/53/850S/1999/231 ថ្ងៃទី១៨ កុម្ភៈ ១៩៩៩ កថាខណ្ឌ១៣៤ ទំព័រ៤៩ និង៥០។